**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

ថ្ងៃច័ន្ទ ១០កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
ភ្នំពេញ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨

**សូមគោរពជូន**
**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិ គ.ជ.ប.ជ**
**ជាទីគោរព**

**កម្មវត្ថុៈ** របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន លើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
**តាមរយៈៈឯកឧត្តមនាយឧត្តមសេនីយ៍ អគ្គលេខាធិការ**នៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ។

តបតាមកម្មវត្ថុ នាងខ្ញុំ មានកិត្តិយសសូមគោរពរាយការណ៍ជូន **លោកជំទាវអនុប្រធានអចិន្ត្រៃយ៍** ថា៖

- កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ សៀមរាប រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋប្រជាមានិតចិនបានចុះសន្ធិសញ្ញាបត្យាប័ន ដើម្បីជំរុញកិច្ចសហប្រតិបត្តិការមានប្រសិទ្ធិភាពរវាងប្រទេសទាំងពីរ ក្នុងការកំចាត់ឧក្រិដ្ឋកម្ម ឈរលើមូលដ្ឋានគោរពអធិបតេយ្យភាពគ្នាទៅវិញទៅមក សមភាព និងផលប្រយោជន៍ទាំងសងខាង ។
- នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ នៅខេត្តសៀមរាប រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋប្រជាមានិតចិន បានរៀបចំកិច្ចប្រជុំស្តីពី ការពង្រឹងកិច្ចសហប្រតិបត្តិ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ ភាគីទាំងពីក៏បានរៀបចំ សេចក្តីព្រាងផែនការសកម្មភាពរួមក្រោមកិច្ចព្រមព្រៀងទ្វេភាគីរវាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិននិងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាលើការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការប្រឆាំងការជួញដូរមនុស្ស ។
- ក្រុមការងារនៃព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋប្រជាមានិតចិនបានប្រជុំប្រចាំឆ្នាំលើកទី១ បន្ទាប់ពីកិច្ចប្រជុំនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់ និងបង្រ្កាបអំពើជួញដូរមនុស្សរវាងអន្តររដ្ឋាភិបាលចិន-កម្ពុជា កាលពីថ្ងៃទី២១ ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ នៅទីក្រុង HoungShan ខេត្ត AnHui ប្រទេសចិន ។
- ជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ២០០៦ ក្រុមការងារ ខមមីត បានរៀបចំកិច្ចប្រជុំផ្លាស់ប្តូរវេនគ្នានៅក្នុងក្រុមប្រទេសសមាជិកទាំង៦ (កម្ពុជា ឡាវ ភូមា ថៃ វៀតណាម និងចិន) ។ កាលពីឆ្នាំ២០១៥ កិច្ចប្រជុំខួប

ទី១០ ព្រះរាជាណាចក្រកម្ពុជាជាម្ចាស់ផ្ទះ ឆ្នាំ២០១៦នៅប្រទេសឡាវ ឆ្នាំ២០១៧នៅប្រទេសភូមា និង ឆ្នាំ២០១៨ នៅខែវិច្ឆិកា កិច្ចប្រជុំនិងប្រព្រឹត្តទៅដោយសាធារណៈរដ្ឋប្រជាមានិតចិនជាម្ចាស់ផ្ទះ ។

- កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋប្រជាមានិតចិន បានចុះកិច្ចព្រមព្រៀង ស្តីពី ការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយមានលោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍នៃអគ្គលេខាធិការដ្ឋាន គជបជ ជាតំណាងដ៏ខ្ពង់ខ្ពស់ បន្ទាប់ពីបានទទួលការអនុញ្ញាតពីសម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោក។

អាស្រ័យហេតុនេះសូម **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ ។

**អគ្គលេខាធិការរង**

រ៉ែន សិរីលក្ខិណា

**ឯកសារជូនភ្ជាប់៖**

- កិច្ចព្រមព្រៀង ស្តីពី ការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ជាភាសាខ្មែរ និងអង់គ្លេស) មួយច្បាប់
- របាយការណ៍លទ្ធផលចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី១ ឆ្នាំ២០១៧ រវាងប្រទេសកម្ពុជា និងប្រទេសចិន មួយច្បាប់
- Draft Joint Plan of Action under the Bilateral Agreement មួយច្បាប់
- សន្ធិសញ្ញាស្តីពីបត្យាប័ន មួយច្បាប់

ចម្លងជូន៖

- ការិយាល័យលោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គជបជ
- ការិយាល័យឯកឧត្តមនាយឧត្តមសេនីយ៍ អគ្គលេខាធិការ គជបជ
- ឯកសារកាលប្បវត្តិ

# មាតិកា

- បត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ចុះថ្ងៃ០៩ ខែកុម្ភៈ ឆ្នាំ ១៩៩៩។

- រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋប្រជាមានិតចិន ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ធ្វើនៅខេត្តសៀមរាប ថ្ងៃទី ២៦ខែសីហា ឆ្នាំ ២០១៦។

- DRAFT Joint Plan of Action under the Bilateral Agreement between the Government of the People's Republic of China and the Government of the Kingdom of Cambodia on Strengthening Cooperation in Counter Trafficking in Persons.

- របាយការណ៍លទ្ធផលចូលរួមកិច្ចប្រជុំប្រចាំលើកទី១ឆ្នាំ២០១៧ ស្តីពីការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរ មនុស្ស រវាងអន្តររដ្ឋាភិបាលចិន-កម្ពុជា (ពីថ្ងៃទី ២១ ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ ទីក្រុង HoungShan ខេត្ត AnHui ប្រទេសចិន) ថ្ងៃទី ២៨ ខែមីនា ឆ្នាំ ២០១៧។